ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

## សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលសំខាន់ៗនៃជំនួបរវាង សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោកជំទាវ អនុរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក Wendy Ruth Sherman

នៅរសៀលថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២១ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យ**លោកជំទាវ វិនឌី រូត្ស ស៊ើមែន** (Wendy Ruth Sherman) អនុរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក ចូលជួបសម្តែងការគួរសម នៅវិមានសន្តិភាព រាជធានីភ្នំពេញ។

នៅក្នុងជំនួបនោះ **លោកជំទាវ ស៊ើមែន** បានពាំនាំនូវសារលិខិតរបស់**ឯកឧត្តម ចូ បៃដិន** (Joe Biden) ប្រធានាធិបតីសហរដ្ឋអាមេរិក ជូន**សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលបង្ហាញអំពីបំណងប្រាថ្នារបស់ឯកឧត្តមប្រធានាធិបតី ក្នុងការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងរវាងប្រទេសទាំងពីរ។ **លោកជំទាវ**បានសម្តែងនូវការពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងសហរដ្ឋអាមេរិក លើទិដ្ឋភាពជាច្រើន រួមមាន ពាណិជ្ជកម្ម និងការវិនិយោគ កម្មវិធីរុករកអដ្ឋិធាតុទាហានអាមេរិកដែលបាត់ខ្លួននៅក្នុងប្រទេសកម្ពុជា (POW/MIA program) ការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម និងកិច្ចការមនុស្សធម៌ ជាពិសេសការអនុញ្ញាតឱ្យនាវាទេសចរណ៍ Westerdam ចូលចតនៅកំពង់ផែកម្ពុជា ។ **លោកជំទាវ**បានជម្រាបជូន**សម្តេចតេជោ**បន្ថែមទៀតអំពីកាលានុវត្តភាពជាច្រើនស្ថិតក្រោមកិច្ចសហប្រតិបត្តិការទ្វេភាគី រួមមាន ការដោះស្រាយបំណុល និងការវិនិយោគរបស់សហរដ្ឋអាមេរិកក្នុងវិស័យប្រេង និងឧស្ម័ន ហេដ្ឋារចនាសម្ព័ន្ធថាមពលបៃតង និងវិស័យផ្សេងៗទៀត។

**សម្តេចតេជោ ហ៊ុន សែន** បានធ្វើការកត់សម្គាល់ប្រកបដោយការពេញចិត្តចំពោះការលើកឡើងរបស់**លោកជំទាវ ស៊ើមែន** និងបានសម្តែងនូវការកោតសរសើរចំពោះការចូលរួមចំណែករបស់សហរដ្ឋអាមេរិកនៅក្នុងដំណើរការស្វែងរកសន្តិភាពនិងការអភិវឌ្ឍសេដ្ឋកិច្ចជាបន្តបន្ទាប់នៅកម្ពុជា ជាពិសេសចំពោះកិច្ចខិតខំប្រឹងប្រែងនាពេលថ្មីៗនេះក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតកូវីដ-១៩ តាមរយៈអង្គការសុខភាព

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh

ពិភពលោក (WHO)។ ឆ្លៀតក្នុងឱកាសនោះផងដែរ **សម្តេចតេជោ** បានសំដែងនូវអំណរសាទរចំពោះរដ្ឋាភិបាលសហរដ្ឋអាមេរិកដែលបានទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ប្រកបដោយជោគជ័យ ដូចដែលបានបង្ហាញឱ្យឃើញច្បាស់ តាមរយៈការចុះថយគួរឱ្យកត់សម្គាល់នូវចំនួនអ្នកឆ្លងជំងឺកូវីដ-១៩ ប្រចាំថ្ងៃ នាពេលថ្មីៗនេះនៅសហរដ្ឋអាមេរិក។

ជាថ្មីម្តងទៀត **សម្តេចតេជោ** បានបញ្ជាក់ច្បាស់អំពីស្ថានភាពនៅមូលដ្ឋានកងទ័ពជើងទឹករាម និងបានរំលឹកពីការប្តេជ្ញាចិត្តដ៏ម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការថែរក្សានិងការពារឯករាជ អព្យាក្រឹត និង អធិបតេយ្យភាពរបស់ខ្លួន ទាំងនយោបាយផ្ទៃក្នុងប្រទេស និង កិច្ចការបរទេស។

**សម្តេចតេជោ** បានស្នើឱ្យរដ្ឋាភិបាលសហរដ្ឋអាមេរិក ពិនិត្យពិចារណាដោះស្រាយបំណុលដែលកម្ពុជាមានចំពោះសហរដ្ឋអាមេរិក តាមវិធីទ្វេភាគី៖

ទី១) អនុញ្ញាតឲ្យកម្ពុជាសងប្រាក់បំណុលនេះតាមកម្មវិធីសងឡើងវិញបន្តិចម្តងៗ

ទី២) សងបំណុលតាមកម្មវិធីដែលមានការប្រាក់មិនលើសពី១ភាគរយ និង

ទី៣) បំណុលដែលកម្ពុជាជំពាក់សហរដ្ឋអាមេរិកគឺសំណងចំនួន ៧០% ត្រូវបង្វិលមកធ្វើជាជំនួយដល់កម្ពុជាវិញ ទៅលើវិស័យអប់រំ វិស័យវប្បធម៌ វិស័យដោះមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះជាដើម។

**សម្តេចតេជោ** បានជម្រាបជូន **លោកជំទាវ ស៊ើមែន** ពីការប្តេជ្ញារបស់រាជរដ្ឋាភិបាលចំពោះកម្មវិធីមាតុភូមិនិវត្តពលរដ្ឋលើការបញ្ជូនជនជាតិកម្ពុជាពីសហរដ្ឋអាមេរិកមកកម្ពុជាវិញ ដោយផ្អែកលើគោលការណ៍គោរពសិទ្ធិមនុស្ស លើទិដ្ឋភាពមនុស្សធម៌ និង មេត្តាករុណាធម៌។

ជាការឆ្លើយតប **លោកជំទាវ** បានថ្លែងអំណរគុណ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចំពោះកិច្ចសហប្រតិបត្តិការទ្វេភាគីនៅលើគ្រប់វិស័យ ហើយ**លោកជំទាវ**បានសន្យាថា នឹងយកសំណើនានាដែលបានលើកឡើងដោយ **សម្តេចតេជោ** ទៅជម្រាបជូន **ឯកឧត្តមប្រធានាធិបតី ចូ បៃដិន** ៕

ថ្ងៃពុធ ៧រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១